


អង្គការរុឺម៉កកង់បី
សម្រាប់កុមារ R4C

សូមស្កេនQR Code

គំនូរជីវចល ធនធានបង្រៀន

Written by TukTuk

Illustrated by Hen Choven



រតនានិងមករាជាបងប្អូននឹងគ្នា។ ថ្ងៃមួយ កុមារទាំងពីរកំពុងលេងជាមួយមិត្តភក្តិនៅក្បែរផ្ទះដូចសព្វមួយដង។
រតនាសួរ « ហ្ហេ! តើពួកឯងធ្លាប់ឃើញយក្សចម្លែកទេ? »
មករាឆ្លើយ « ខ្ញុំមិនដែលឃើញទេ បងប្រាប់ខ្ញុំផងមើល! »
រតនាតបវិញ « គាត់បើក៊ីម៉កកង់បី ហើយគ្រប់គ្នាហៅគាត់ថា យក្ស »។
មករាសួរទៀត « មាឌគាត់ធំទេ? »



រតនាឆ្លើយ « បងឮគេថាមាឌគាត់ធំ ហើយខ្ពស់ប៉ុនដើមត្នោតហ្នំ ហើយស្បែកជើងគាត់ធំប៉ុនទូក... »



ហើយគាត់ចូលចិត្តញុំាក្មេងៗជាអាហារ។
មករាភ្លាត់មាត់ « អ្ហា៎ ញុំាក្មេងៗ! ខ្ញុំមិនចង់ជួបគាត់ទេ »។



ថ្ងៃមួយ រតនានិងមករាបានបែកកង់ពេលកំពុងជិះតាមផ្លូវពីសាលារៀនត្រឡប់ទៅផ្ទះវិញ។
រតនានិងមករាមិនដឹងធ្វើយ៉ាងម៉េច ក៏អង្គុយចាំនៅតាមផ្លូវក្បែរមាត់ទឹក រង់ចាំក្រែងលោមាននរណាម្នាក់ជិះកាត់
ដើម្បីសុំដោយសារ។



មិនយូរប៉ុន្មាន រ៉ឺម៉កកង់បីមួយបានបើកមកដល់។ កុមារទាំងពីរបក់ដៃឃាត់រ៉ឺម៉កកង់បី។
រ៉ឺម៉កកង់បីនោះមានពណ៌ខៀវ ហើយអ្នកបើកក៏ពាក់មួកការពារសុវត្ថិភាពពណ៌ខៀវដែរ។ នៅបាំងខាងក្រោយមានសត្វ
អ្វីម៉្យាងដែលកុមារទាំងពីរមិនដែលស្គាល់។
រតនានិងមករាមានអារម្មណ៍ភ័យតិចៗ។



ពេលដែលរ៉ឺម៉កកង់បីឈប់ រតនានិងមកាសង្កេតឃើញថា អ្នកបើករ៉ឺម៉កកង់បីមានជើងធំណាស់។



ពេលដែលគាត់ចុះពីលើរ៉ឺម៉កកង់បី គាត់ឈរខ្ពស់ឡើងជម្រោង។
រតនានិងមករាកាន់តែភ័យថែមទៀត។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



អ្នកបើករ៉ឺម៉កកង់បីដោះមួកការពារសុវត្ថិភាពចេញ...

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



...គាត់មានមុខចម្លែកខ្លាំងណាស់!
រតនានិងមករាភិតភ័យកាន់តែខ្លាំង។



អ្នកបើករ៉ឺម៉កកង់បីនិយាយទាំងសម្លេងធំៗ « សួស្តី! ខ្ញុំឈ្មោះយ៉េក! មានអ្វីឱ្យខ្ញុំជួយទេ? »
រតនានិងមករាងើយមុខមើលទៅយ៉េក ហើយខ្សឹបគ្នា « តើគាត់និយាយថាគាត់ឈ្មោះយក្សមែនទេ?
អ្ហឺយ! ខ្ញុំគិតថាយើងគួរតែរត់ទៅល្អជាង »។



យ៉េក ឮអ្វីដែលក្មេងៗខ្សឹបគ្នា។
គាត់តប « កុំបារម្ភអីណាក្មេងៗ! ខ្ញុំមិនមែនជា យក្សទេ! ខ្ញុំឈ្មោះយ៉េកទេតើ »។
វតនានិងមករានៅតែភ័យខ្លាចដដែល។



អ្នកដែលអង្គុយនៅបាំងខាងក្រោយរ៉ឺម៉កកង់បីក៏ចុះមក « សួស្តី! ខ្ញុំឈ្មោះខេទី! ខ្ញុំគឺជាសត្វ ខូអាឡា! តើអ្នកទាំងពីរឈ្មោះអ្វីដែរ? »

រតនាតបវិញ « ខ្ញុំមិនអាចប្រាប់ឈ្មោះរបស់ខ្ញុំទៅអ្នកបានទេ ព្រោះថា អ្នកគឺជាមនុស្សចម្លែក... »

រតនានិងមករាកាន់តែភ័យខ្លាំងឡើងៗ។ កុមារទាំងពីរមិនដឹងធ្វើយ៉ាងម៉េច ដើម្បីរត់គេចឱ្យឆ្ងាយពីមនុស្សចម្លែកទាំងពីរនាក់នោះទេ។



« ពីបៗ! ពីបៗ! »
ពួកគេបានឮសំឡេងស៊ីប្លេម៉ូតូ ហើយបុរសម្នាក់ក៏បន្លឺសំឡេងឡើង
« សួស្ដី យ៉េក! សួស្ដី ខេទី! សួស្ដីក្មេងៗ! ទាំងអស់គ្នាសុខសប្បាយជាទេ? »
មករា ងាកទៅទាំងភ្ញាក់ផ្អើល « អូ! លោកគ្រូតើ! ជម្រាបសួរលោកគ្រូ តើលោកគ្រូស្គាល់យ៉េកនិងខេទីដែរមែនទេ?.
លោកគ្រូសុខឆ្លើយ « បាទស្គាល់!ពួកយើងគឺជាមិត្តភក្តិនឹងគ្នាទៀតផង »

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



លោកគ្រូសុខសួរមករានិងរតនា « តើអ្នកទាំងពីរនាក់កំពុងធ្វើអ្វីហ្នឹង? »
រតនាឆ្លើយ « ចាសលោកគ្រូ កង់របស់ខ្ញុំបានបែក ហើយពួកខ្ញុំកំពុងរង់ចាំក្រែងមានអ្នកណាម្នាក់មកជួយពួកខ្ញុំហ្នឹងណា ហើយយ៉េកនិងខេទីក៏បានមកដល់ »។
មករាលួចសួរលោកគ្រូសុខខ្សឹបៗ « លោកគ្រូៗ! តើយ៉េកចូលចិត្តញុំាក្មេងៗជាអាហារមែនទេ? »
លោគ្រូសុខឆ្លើយទាំងអស់សំណើច « អត់ទេ! អត់ទេ! វាមិនមែនជាការពិតនោះទេ »។



យ៉េកឮដូចនេះ ក៏និយាយតៈ « កុំយល់ច្រឡំនឹងខ្ញុំអី! ខ្ញុំមិនចូលចិត្តញ៉ាំក្មេងៗទេ តែខ្ញុំចូលចិត្តញ៉ាំភីហ្សានិងផ្លែឪឡឹក »។ ទាំងអស់គ្នាសើចគឹល... « ហាសហា ហិហិ »។



យ៉េកសួររតនានិងមករា « តើអ្នកទាំងពីរឈ្មោះអ្វីដែរ? »
កុមារទាំងពីរឆ្លើយបន្តបន្ទាប់គ្នា « ខ្ញុំឈ្មោះ រតនា ចំណែកខ្ញុំឈ្មោះ មករា »។
យ៉េកបន្ត « អូ! រីករាយណាស់ដែលបានស្គាល់ រតនានិងមករា! ចាំខ្ញុំជូនអ្នកទាំងពីរទៅផ្ទះណ៎ា! »



ទាំងអស់គ្នាក៏ជម្រាបលាលោកគ្រូសុខ។ យ៉េកបានចងកង់របស់រតនានិងមករា នៅពីក្រោយរ៉ឺម៉កកង់បី។
បន្ទាប់មក កុមារទាំងពីរក៏ឡើងលើរ៉ឺម៉កកង់បី ហើយយ៉េក ក៏បើកវាចេញទៅ។
រតនានិងមករាជជែកលេងជាមួយ ខេទីតាមផ្លូវរហូតដល់ផ្ទះ។
ខេទីបាននិយាយប្រាប់កុមារទាំងពីរអំពីប្រទេស អូស្ត្រាលីដែលជាកន្លែងកំណើតរបស់គាត់និងយ៉េក។
រតនានិងមករាមានសំណួរជាច្រើនដែលចង់សួរទៅកាន់គាត់ ប៉ុន្តែពេលវេលាខ្លីពេក រ៉ឺម៉កកង់បីក៏បានទៅដល់ផ្ទះរបស់ពួកគេ។



រតនានិងមករាលោតចុះពីលើរ៉ឺម៉កកង់បី « អរគុណច្រើន យ៉េកនិងខេទី! ថ្ងៃក្រោយជួបគ្នា! »
ហើយរតនានិងមករាក៏រត់ទៅលេងជាមួយមិត្តភក្តិរបស់ពួកគេបាត់ទៅ។



រតនាបានប្រាប់មិត្តភក្តិរបស់ពួកគេ « ពួកខ្ញុំបានជួបយក្សចម្លែកនោះហើយ មាឌគាត់ធំ ហើយខ្ពស់មែន តែមិនមែនខ្ពស់ដូចជាដើមត្នោតនោះទេ ស្បែកជើងគាត់ក៏ធំដែរ តែមិនមែនធំប៉ុនទូកនោះទេ ហើយគាត់ក៏មិនមែនញ៉ាំក្មេងៗជាអាហារដែរ តែគាត់ចូលចិត្តញ៉ាំភីហ្សានិងផ្លែឪឡឹកតែប៉ុណ្ណោះ គាត់ឈ្មោះថា យ៉េក មិនមែនឈ្មោះថា យក្សនោះទេ មិត្តភក្តិរបស់គាត់ឈ្មោះ ខេទី គឺជាសត្វ ខូអាឡា ហើយពួកគេក៏ជាមិត្តភក្តិរបស់លោកគ្រូសុខផងដែរ »។



មករាបន្តទៀត « ខ្ញុំចង់ជួបពួកគាត់ម្ដងទៀតក្នុងពេលឆាប់ៗនេះ »។
ក្មេងៗទាំងអស់ក៏បន្ទរ « មែនហើយៗ! សូម្បីតែពួកយើងក៏ចង់ជួបពួកគាត់ដែរ »។
ចប់ដោយបរិបូរណ៍។